# Living the Lotus

## Buddhism in Everyday Life

4
2025
VOL. 235





Rissho Kosei-kai of Brazil

Living the Lotus
Vol. 235 (April 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.



# ដែលហៅថាជំនឿនិងការគោរព

ព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីស្សូកូសេកៃ

## អ្វីទៅដែលហៅជំនឿ ?

ចំពោះពុទ្ធសាសនិកថ្ងៃប្រសូតរបស់ព្រះសម្មា សម្ពុទ្ធជាថ្ងៃដែលមានន័យជ្រាលជ្រៅណាស់ ។ នៅប្រទេសជប៉ុន ពុទ្ធសាសនិកកំណត់ថ្ងៃទី៨ខែមេសាប្រារព្ធពិធីបុណ្យរំលឹកថ្ងៃប្រសូតរបស់ព្រះអង្គ។

នៅក្នុងពាក្យកាព្យរបស់លោកម៉ូរី ស៊ីមីអូដែលសរសេរថា “នៅថ្ងៃដែលខ្ញុំកើត ម្តាយឪពុកក៏ធ្វើបុណ្យរំលឹកថ្ងៃខួបកំណើតព្រះសម្មាសម្ពុទ្ធតូចមួយឱ្យ“ ក៏មានពាក្យបុណ្យរំលឹកខួបកំណើតព្រះសម្មាសម្ពុទ្ធដែរ។ បុណ្យសុគន្ធវារី (ស្រង់ទឹកព្រះ) ក្តី,បុណ្យរំលឹកថ្ងៃប្រសូតនៃព្រះសម្មាសម្ពុ ទ្ធក្តី បុណ្យផ្កាជប៉ុនក្តី គឺសុទ្ធតែជាពិធីសាសនាដែលប្រារព្ធឡើងដើម្បីរំលឹកខួបកំណើតរបស់ព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូនៃយើង។បើមើលទៅកំណាព្យរបស់លោកម៉ូរី យើងដឹងថានៅថ្ងៃនោះនៅវត្តអារាមគេមានធ្វើកូនរានទេវតាដែលលំអដោយផ្កាតំណាងឱ្យសួនលុម្ពិនីដែលព្រះពុទ្ធទ្រង់ប្រសូត្រ។ អ្នកដែលមកចូលរួបរួមទទួលទានទឹកតែផ្អែមដែលនាំឱ្យករីចាប់ភ្លឹកហើយមានអារម្ម ណ៍រំភើបថានៅថ្ងៃប្រសូត ព្រះសម្មាសម្ពុទ្ធដ៏តូចដូចរូបខ្លួនដែរ។ ខ្លួនក៏បានទទួលជីវិតមួយដែលមានតម្លៃដូចតែជីវិតរបស់ព្រះសម្មាសម្ពុទ្ធដែរ។

ដូចដែលបន្ទូលដែលទ្រង់មាននៅពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត្រភ្លាមទ្រង់យាងទៅមុខ៧ជំហានលើកម្រាមដៃស្តាំចង្អុរទៅលើហើយមានពុទ្ធដីកាថា៖ “ក្រោមមេឃលើដីមានតែយើងជាមនុស្សតែមួយគត់ដែលមានតម្លៃកាត់ថ្លៃមិនបាន“ ។ដែលមានន័យថា “ចូរយើងដឹងគុណឱ្យបានដិតដល់ចំពោះភាពថ្លៃថ្លាដោយបានកើតមកជាមនុស្ស“ ។ព្រះស្ថាបនិកកៃសូសាម៉ាបានមានសង្ឃដីកាថា“ យើងមានអារម្មណ៍កក់ក្តៅក្នុងចិត្តហើយបេះដូងយើងដង្ហើមយើងតែងតែផ្ជាប់ជាមួយនឹងព្រះសម្មាសម្ពុទ្ធ“ ។នោះហើយដែលហៅថា“ ជំនឿពីបេះដូង“ ។ដូច្នេះហើយបុណ្យរំលឹកថ្ងៃប្រសូតរបស់ព្រះសម្មាសម្ពុទ្ធនេះជាឱកាសសម្រាប់ឱ្យយើងម្នាក់ៗគិតពីតម្លៃកាត់ថ្លៃមិនបាននៃជីវិតរបស់ខ្លួននិងអ្នកដទៃហើយថ្លែងអំណរគុណចំពោះជីវិតដែលបានផ្តល់មកឱ្យនោះគឺជាការប្រសើរខ្លាំងណាស់។

លើសពីនេះទៅទៀតកៃសូសាម៉ាបានអធិប្បាយថា“ ជំនឿបង្រៀនពីវិធីរស់នៅពិតៗ“ ដែលមានន័យថាសាសនានិងជំនឿបង្រៀនយើងពីមូលដ្ឋានគ្រឹះនៃជីវភាពនិងព្រលឹងស្មារតីរបស់មនុស្សហើយមូលដ្ឋានបាតគ្រឹះបំផុតនោះគឺ“ ជីវិតដែលមានតម្លៃកាត់ថ្លៃមិនបានរបស់ខ្លួននិងគុណូបការគុណចំពោះការដែលបានកើតមកជាមនុស្ស“ ។

ម្យ៉ាងវិញទៀតក្រោយពេលដែលព្រះសម្មា សម្ពុទ្ធទ្រង់ប្រសូតបាន៧ថ្ងៃ ព្រះវរមាតាព្រះនាងសិរីមហាមាយាទ្រង់ក៏សោយទីវង្គត។នេះជានិមិ ត្តរូបនៃកើត ចាស់ ឈឺ ស្លាប់។នៅក្នុងលោកនេះគ្មានអ្វីទៀងទាត់ទេ អ្វីៗតែងតែប្រែប្រួល

គឺជាសច្ចធម៌ (អនិច្ចំ) ព្រមទាំងបង្ហាញថាគ្រប់បាតភូតិទាំងអស់សុទ្ធតែកើតចេញពីប្រតិកម្មដែលកើតពីទំនាក់ទំនងគ្នាទៅវិញទៅមកនៃដើមហេតុនិងបច្ច័យ (គ្មានអាត្មា--សូន្យ) ដែលជាសច្ចធម៌។យើងគោងតែទទួលដោយមិនរឹងរូសហើយរស់នៅដោយសុខដុំរមនាជាមួយនឹងអ្នកដទៃ។នេះហើយដែលហៅថា□របៀបរស់នៅប្រាកដប្រជារបស់មនុស្ស ”។

ពោលគឺថាយើងរៀនរបៀបរស់នៅ យោលទៅតាមការបង្រៀនរបស់ព្រះពុទ្ធដែលជាត្រីវិស័យដ៏មានតម្លៃជឿហើយគោរព។នេះជាប្រការនាំផ្លូវឱ្យបានទៅដល់ការលូតលាស់របស់យើង។ហ្នឹងហើយដែលគេហៅថា “ជំនឿ” ហើយកិច្ចប្រតិបត្តិបែបច្នៃប្រឌិតមួយគឺកិច្ចប្រតិបត្តិព្រះពោធិសត្វដែលយើងប្រព្រឹត្តរាល់ថ្ងៃនោះឯង។

## មិនត្រូវរេរាតាមការប្រែប្រួលនៃសម័យកាលឡើយ

សព្វថ្ងៃនេះមានករណីមួយដែលបានក្លាយជាបញ្ហាសង្គមគឺ “របរស៊ីឈ្នួលផ្លូវងងឹត” ដូចជាទូរស័ព្ទទៅបោកប្រាស់ឬសម្លាប់អ្នកដទៃដើម្បីបានប្រាក់ឈ្នួលថ្លៃ។ពាក់ព័ន្ធនឹងបញ្ហានេះមានពុទ្ធសាសនិកដែលជាសមាជិកនៃសមាគមយើងម្នាក់គាត់បាននិយាយជាមួយនឹងកូនស្រីគាត់។គាត់សួរកូនស្រីគាត់ថា៖ “ចុះហេតុអ្វីបានជាយុវជនសម័យនេះអាចលើកដៃទៅឆក់ប្លន់ឬសម្លាប់គេធូរៗម្ល៉េះ? “កូនស្រីគាត់បានឆ្លើយយ៉ាងធម្មតាមកវិញថា៖” មកពីគេគ្មានជំនឿទៅលើសាសនានៅក្នុងខ្លួននោះឯង“។

នៅពេលដែលមានជំនឿទៅលើសាសនាយើងក៏ចាប់ភ្លឹកថាជីវិតមានតម្លៃឥតអាចកាត់ថ្លៃបានទេ ហើយអាចដឹងថាយើងតែម្នាក់ឯងមិនអាចរស់នៅដោយកម្លាំងខ្លួនឯងកើតឡើយដូច្នេះហើយយើងក៏មានសមានចិត្តចំពោះអ្នកដទៃហើយចង់ឱ្យអាចធ្វើអ្វីមួយជាប្រយោជន៍ចំពោះគេឯងបាន។យើងមិនអាចទៅបោកប្រាស់លួចប្លន់ឬសម្លាប់អ្នកដទៃបានទេផ្ទុយទៅវិញយើងចង់តែធ្វើអំពើល្អជាប្រយោជន៍ដល់គេ។នោះគឺ“ស្នូលនៃរបៀបរស់នៅ“។ព្រលឹងនេះដុះដាលនៅលើ“ថ្នាល“នៃ“គ្រួសារដែលមានជំនឿ“ដែលយើងអាចត្រងត្រាប់បានពីសម្ដីរបស់កុមារីជាកូនស្រីនៃសមាជិកសមាគមយើងនោះ។

ក៏ប៉ុន្តែក៏មិនមែនមានន័យថាបើមានជំនឿលើសាសនាយើងមិនអាចធ្វើអំពើបាបឬក៏បើយើងជឿទៅលើសាសនាយើងនឹងអាចចៀសផុតពីការធ្លាក់ខ្លួនក្រឬក៏ឈឺឡើយគឺបានន័យថាការបង្រៀនដ៏ថ្លៃថ្លាដែលប្រាប់ពីរបៀបរស់នៅដ៏ពិតប្រាកដ=នៅក្នុងជំនឿនិងការគោរពវន្ទាទៅលើសាសនានាំឱ្យយើងបានរៀនសូត្រច្រើន ហើយអាចសំដៅឆ្ពោះទៅរកការលូតលាស់ទៅមុខក្នុងនាមជាមនុស្សបាន។

នៅក្នុងសម័យកាលដែលសម្បូរបែបដូចសព្វថ្ងៃអ្នកដទៃមើលមកសាសនាដោយភ្នែកតឹងរ៉ឹងជាខ្លាំង។ក៏ប៉ុន្តែនៅក្នុងជម្រៅបេះដូងឯនោះវិញមនុស្សម្នាក់ណាក៏ពិតជាចង់ដឹងចង់រៀនពីការបង្រៀននៃសាសនាដែលខ្លួនអាចជ្រកជាទីរំពឹងដ៏កក់ក្ដៅនិងមានចិត្តសង្ឃឹមចង់លូតលាស់ទៅលើជាខ្លាំង។ដូច្នេះគេគឺជាអ្នកមានជំនឿទៅលើសាសនារួចស្រេចទៅហើយ។

ឈរលើទស្សនៈបែបនេះអ្វីដែលសំខាន់មិនមែនមធ្យោបាយដែលនឹកឃើញភ្លាមៗនោះទេអ្វីដែលសំខាន់គឺត្រូវទៅជាមនុស្សដែលមានបេះដូងមេត្តាករុណាដ៏ស្មោះនិងសមានចិត្តជាមួយនឹងមនុស្សនានាដែលជាបាតគ្រឹះនៃព្រះពុទ្ធសាសនាហើយនៅពេលដែលមានអ្វីកើតឡើងភ្លាម ៗយើងអាចបោះដៃទៅជួយគេបាន។នៅទីនោះប្រសិនបើមានអារម្មណ៍ថាស្ងប់ចិត្តគឺមានន័យថាតាំងពីដំបូងមកម្ល៉េះអ្នកមានជំនឿទៅលើសាសនាហើយកំពុងតែត្រូវបានដឹកដៃយ៉ាងធម្មតាទៅរក“ការរស់នៅប្រកបដោយភាពប្រាកដប្រជា” ហើយ។



『កូសេ』 លេខខែមេសា ឆ្នាំ២០២៥




# A Global Buddhist Movement




Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp